នស/រកម/១០០៥/០២៦

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃអនុសញ្ញាស្តីពីការបង្ក្រាប *អំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែ* សីហា ឆ្នាំ ២០០៥ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុងកាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃ អនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃ ការធ្វើនាវាចរណ៍តាមដែនសមុទ្រ

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ដែលធ្វើនៅទីក្រុងរ៉ូម នាថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៨៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

**មាត្រា ៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

នស/រកម/១០០៥/០៤៦ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
ហត្ថលេខា
ទៀ បាញ់ ញឹក ប៊ុនឆៃ

លេខ: ៣៩៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ ១០ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង តាន់

# អនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ

**រដ្ឋភាគីនានាទាំងឡាយនៃអនុសញ្ញានេះ:**

-ដោយបានយកចិត្តទុកដាក់លើវត្ថុបំណង និង គោលការណ៍ទាំងឡាយនៃធម្មនុញ្ញសហប្រជាជាតិទាក់ទងទៅនឹងការរក្សាសន្តិភាព និង សន្តិសុខអន្តរជាតិ និងការជំរុញទំនាក់ទំនងជាមិត្តភាព និង កិច្ចសហប្រតិបត្តិការរវាងរដ្ឋនានា

-ដោយបានទទួលស្គាល់ជាពិសេសថាមនុស្សគ្រប់រូបមានសិទ្ធិខាងការរស់រានមានជីវិត មានសិទ្ធិខាងសេរីភាព និង មានសន្តិសុខផ្ទាល់ខ្លួន ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និង ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ

-ដោយមានការព្រួយបារម្ភយ៉ាងខ្លាំង អំពីការកើនឡើងទូទាំងពិភពលោក នូវអំពើភេរវកម្មតាមគ្រប់រូបភាពដែលអាចបង្កគ្រោះថ្នាក់ ឬ ក៏ធ្វើអោយបាត់បង់អាយុជីវិតដល់ជនស្លូតត្រង់ ធ្វើឱ្យគ្រោះថ្នាក់ដល់សេរីភាពជាមូលដ្ឋាន និង ធ្វើឱ្យអាប់អោនយ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ

-ដោយយល់ឃើញថា អំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ បង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពបុគ្គលនិងទ្រព្យសម្បត្តិ ធ្វើអោយប៉ះពាល់រំខានយ៉ាងខ្លាំងដល់ប្រតិបត្តិការសេវាកម្មតាមដែនសមុទ្រ និង បន្ថយជំនឿទុកចិត្តរបស់មនុស្សនៅលើពិភពលោក ចំពោះសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ

-ដោយយល់ឃើញថា ការកើតមានឡើងនូវអំពើបែបនេះជាបញ្ហាព្រួយបារម្ភយ៉ាងខ្លាំងមួយ ដល់សហគមន៍អន្តរជាតិទាំងមូល

-ដោយជឿជាក់ចំពោះភាពចាំបាច់ជាបន្ទាន់ដើម្បីអភិវឌ្ឍកិច្ចសហប្រតិបត្តិការអន្តរជាតិមួយរវាងរដ្ឋនានា ក្នុងការបង្កើត និង អនុម័តនូវវិធានការជាក់ស្តែងនិងមានប្រសិទ្ធិភាពទាំងឡាយក្នុងការទប់ស្កាត់រាល់អំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ និង ការចោទប្រកាន់និងការដាក់ទោសដល់អ្នកប្រព្រឹត្តបទល្មើស (ចរី)

-ដោយរំលឹកឡើងវិញនូវសេចក្ដីសំរេចលេខ ៤០/៦១ របស់មហាសន្និបាតសហប្រជាជាតិចុះថ្ងៃទី ០៩ ធ្នូ ១៩៨៥ "ដែលតាមសេចក្ដីសំរេចនេះ ស្នើដោយទទូចដល់គ្រប់រដ្ឋទាំងអស់ ដោយឯកតោភាគីក្ដី និងក្នុងកិច្ចសហប្រតិបត្តិការជាមួយបណ្ដារដ្ឋផ្សេងៗទៀតក្ដី ព្រមទាំងស្នើដល់ស្ថាប័នមានសមត្ថកិច្ចទាំងឡាយរបស់អង្គការសហប្រជាជាតិ ដើម្បីរួមចំណែកលុបបំបាត់ជាលំដាប់នូវបុព្វហេតុផ្សេងៗ ដែលជាប្រភពកំណើតនៃភេរវកម្មអន្តជាតិ និងដើម្បីប្រុងប្រយ័ត្នជាពិសេសដល់ស្ថានភាពទាំងឡាយ រួមមានអាណានិគមនិយម ជាតិសាសន៍និយម និងស្ថានភាពនានា ដែលសំដែងអោយឃើញនូវការរំលោភបំពានទ្រង់ទ្រាយធំ(mass) និងជាក់ស្ដែងទៅលើសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន និងស្ថានភាពទាំងឡាយដែលជាប់ទាក់ទងនឹងការកាន់កាប់ពីបរទេស ដែលអាចបង្កអោយមានអំពើភេរវកម្មអន្តជាតិ និង អាចធ្វើអោយមានគ្រោះថ្នាក់ដល់សន្តិភាព និង សន្តិសុខអន្តរជាតិ " ។

-ដោយរំលឹកឡើងវិញបន្ថែមទៀតនូវសេចក្ដីសំរេចលេខ ៤០/៦១ ស្ដីពីការ "ថ្កោលទោសដោយឥតសង្ស័យ/ឥតព្រលាំ ថាជាឧក្រិដ្ឋជន អំពើ វិធីសាស្ត្រ និង ការអនុវត្តន៍ទាំងឡាយនៃភេរវកម្ម នៅទីកន្លែងណាក៏ដោយ និងដោយជនណាក៏ដោយ រួមបញ្ចូលទាំងអំពើទាំងឡាយដែលធ្វើអោយមានគ្រោះថ្នាក់ដល់ទំនាក់ទំនងជាមិត្តភាពរវាងរដ្ឋនានា និង សន្តិសុខរបស់ពួកគេ "។

-ដោយរំលឹកឡើងវិញផងដែរតាមសេចក្ដីសំរេចលេខ ៤០/៦១ ថា អង្គការដែនសមុទ្រអន្តរជាតិត្រូវបានកោះអញ្ជើញដើម្បី "ធ្វើការសិក្សាបញ្ហាភេរវកម្មនៅលើនាវា ឬ ប្រឆាំងនឹងនាវា ក្នុងគោលបំណងបង្កើតឡើងនូវអនុសាសន៍មួយចំនួនលើវិធានការសមស្របនានា "។

-ដោយមានការយកចិត្តទុកដាក់ ចំពោះសេចក្ដីសំរេចលេខ A.៥៨៤(១៤) ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ១៩៨៥ នៃសន្និបាតអង្គការដែនសមុទ្រអន្តរជាតិ ដែលបានអំពាវនាវ(ស្នើសុំ)អោយធ្វើការអភិវឌ្ឍវិធានការផ្សេងៗសំដៅទប់ស្កាត់រាល់អំពើខុសច្បាប់ដែលគំរាមកំហែងដល់សន្តិសុខនៃនាវា និង សុវត្ថិភាពរបស់អ្នកដំណើរ និង ក្រុមនាវិក

-ដោយកត់សំគាល់ថា អំពើទាំងឡាយរបស់ក្រុមនាវិកដែលអាស្រ័យលើវិន័យធម្មតានៅលើនាវា គឺស្ថិតនៅក្រៅការកំណត់(បទប្បញ្ញត្តិ)នៃអនុសញ្ញានេះ

-ដោយអះអាងនូវគោលបំណងនៃវិធាន និង ស្តង់ដារក្នុងការត្រួតពិនិត្យទាំងឡាយ ដែលទាក់ទងទៅនឹងការទប់ស្កាត់ និងការត្រួតពិនិត្យនៃរាល់អំពើខុសច្បាប់ប្រឆាំងនឹងនាវា និងមនុស្សនៅលើនាវា ជាមួយនឹងគោលបំណងមួយដើម្បីផ្សព្វផ្សាយទាន់ពេលវេលានូវវិធាន និងស្តង់ដារទាំងនេះទៅតាមការចាំបាច់ និង ទៅតាមខ្លឹមសារនេះ ដោយកត់សំគាល់ជាមួយការពេញចិត្តចំពោះវិធានការទាំងឡាយ សំដៅទប់ស្កាត់អំពើខុសច្បាប់ប្រឆាំងអ្នកដំណើរ

និងក្រុមនាវិកនៅលើនាវា ដូចដែលបានផ្តល់អនុសាសន៍ដោយគណៈកម្មាធិការសុវត្ថិភាពដែនសមុទ្រនៃអង្គការដែនសមុទ្រអន្តរជាតិ

- ដោយបញ្ជាក់បន្ថែមទៀតថាបញ្ហាទាំងឡាយដែលមិនត្រូវបានចែងដោយអនុសញ្ញានេះ នឹងត្រូវបន្តគ្រប់គ្រងដោយវិធាននិងគោលការណ៍ទាំងឡាយនៃនីតិអន្តរជាតិទូទៅ

-ដោយទទួលស្គាល់នូវភាពចាំបាច់សំរាប់រដ្ឋទាំងអស់ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ដោយគោរពយ៉ាងតឹងរឹងតាមវិធាននិងគោលការណ៍ទាំងឡាយនៃនីតិអន្តរជាតិទូទៅ ។

**បានព្រមព្រៀង** ដូចខាងក្រោមនេះ :

## មាត្រា១

វត្ថុបំណងនៃអនុសញ្ញានេះ "នាវា" មានន័យថាអាគារសមុទ្រនៃប្រភេទណាមួយក៏ដោយដែលមិនស្ថិតជាប់ជាអចិន្ត្រៃយ៍ទៅនឹងបាតសមុទ្រ រាប់បញ្ចូលទាំងនាវាដែលដើរដោយកំលាំងថាមពល នាវាមុជទឹក ឬ នាវាបណ្តែតទឹកផ្សេងៗទៀត ។

## មាត្រា២

១ អនុសញ្ញានេះមិនអនុវត្តចំពោះ :

ក- នាវាចម្បាំង ឬ

ខ- កប៉ាល់ដែលជាកម្មសិទ្ធរបស់រដ្ឋមួយ ឬដែលត្រូវបានប្រតិបត្តិដោយរដ្ឋមួយ នៅពេលដែលនាវាទាំងនោះត្រូវបានប្រើប្រាស់ជានាវាចម្បាំងជំនួយ ឬ សំរាប់គោលដៅគយ ឬនគរបាល ឬ

គ- នាវាដែលត្រូវបានដកចេញពីការធ្វើនាវាចរណ៍ ឬត្រូវបានគេលើកឡើងសំរាប់ជួសជុល ។

២ គ្មានបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះប៉ះពាល់ដល់អភ័យឯកសិទ្ធិនៃនាវាចម្បាំង និង នាវាផ្សេងៗទៀតរបស់រដ្ឋដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងមិនមែនពាណិជ្ជកម្ម ។

## មាត្រា៣

១ ជនណាម្នាក់ជាជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមួយ ប្រសិនបើជននោះប្រព្រឹត្តដោយខុសច្បាប់ និង ដោយចេតនា :

ក- រឹបអូស ឬ ធ្វើការត្រួតត្រាទៅលើនាវាដោយប្រើហឹង្សា ឬ ការគំរាមកំហែង ឬការបំភិតបំភ័យតាមទ្រង់ទ្រាយណាមួយ ឬ

ខ- ប្រព្រឹត្តអំពើហឹង្សាទៅលើមនុស្សនៅលើនាវា ប្រសិនបើអំពើនោះអាចធ្វើអោយមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ ឬ

គ- បំផ្លាញនាវា ឬ បង្កការខូចខាតដល់នាវា ឬទំនិញរបស់នាវាដែលអាចធ្វើអោយគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ ឬ

ឃ- ដាក់ ឬ ធ្វើអោយមានការដាក់នៅលើនាវា ដោយមធ្យោបាយណាក៏ដោយនូវឧបករណ៍ ឬសារធាតុដែលអាចបំផ្លិចបំផ្លាញដល់នាវានោះ ឬដែលអាចបង្កការខូចខាតដល់នាវា ឬទំនិញរបស់នាវានោះ ដែលធ្វើអោយគ្រោះថ្នាក់ ឬអាចធ្វើអោយ គ្រោះថ្នាក់ដល់សុវត្ថិភាព នៃការធ្វើនាវាចរណ៍របស់នាវានោះ ឬ

ង- បំផ្លាញ ឬធ្វើអោយខូចខាតយ៉ាងធ្ងន់ធ្ងរដល់ឧបករណ៍សំរាប់ការធ្វើនាវាចរណ៍តាមសមុទ្រ ឬ ធ្វើអោយរំខានយ៉ាងខ្លាំងដល់ប្រតិបត្តិការរបស់នាវា ប្រសិនបើទង្វើបែបនោះអាចធ្វើអោយគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ ឬ

ច- ផ្តល់ពត៌មានដែលខ្លួនដឹងថា "មិនពិត" ដែលជាហេតុធ្វើអោយគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវា ឬ

ឆ- បង្ករបួសស្នាម ឬធ្វើឃាតជនណាម្នាក់ បើអំពើទាំងនោះ មានចំណងទាក់ទងជាមួយនឹងបទល្មើសមួយនៃបទល្មើសទាំងឡាយ ដូចមានចែងក្នុងវាក្យខ័ណ្ឌ (ក) ដល់ (ច) ដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្ត។

២ ចាត់ទុកជាការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមួយផងដែរ ប្រសិនបើជននោះ :

ក- ប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ១ ឬ

ខ- ជំរុញជនណាម្នាក់ផ្សេងទៀត អោយប្រព្រឹត្តបទល្មើសណាមួយ ក្នុងចំណោមបទល្មើសទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ១ ឬសមគំនិតជាមួយនឹងជនណាម្នាក់ដែលប្រព្រឹត្តបទល្មើសបែបណាមួយនោះ ឬ

គ- គំរាមកំហែង ដោយមាន ឬ គ្មានលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ជាតិ ក្នុងគោលបំណងបង្ខិតបង្ខំរូបវន្តបុគ្គល ឬនិតិបុគ្គលអោយធ្វើឬមិនអោយធ្វើនូវអំពើណាមួយ អោយប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងកថាខ័ណ្ឌ១ វាក្យខ័ណ្ឌ (ខ) (គ) និង (ង) ប្រសិនបើការគំរាមកំហែងនោះអាចធ្វើអោយគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ ។

## មាត្រា៤

១ អនុសញ្ញានេះ ត្រូវអនុវត្ត ប្រសិនបើនាវាដែលកំពុងធ្វើនាវាចរណ៍ ឬ ដែលបានកំណត់គំរោងធ្វើដំណើរចូលទៅក្នុង ឬកាត់តាម ឬចេញពីដែនទឹកដែលស្ថិតនៅខាងក្រៅនៃសមុទ្រដែនដីនៃរដ្ឋមួយ ឬនៅខាងដែនកំណត់ម្ខាងទៀតនៃសមុទ្រដែនដីរបស់ខ្លួនដែលជាប់នឹងសមុទ្រដែនដីនៃរដ្ឋផ្សេងទៀត។

២ ក្នុងករណីដែលអនុសញ្ញានេះមិនអនុវត្តទៅតាមកថាខ័ណ្ឌ ១ ប៉ុន្តែបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះអនុវត្ត ប្រសិនបើជនល្មើស ឬ ជនល្មើសដោយសន្មតត្រូវបានរកឃើញនៅក្នុងទឹកដីនៃភាគីរដ្ឋមួយ ក្រៅពីរដ្ឋដែលត្រូវបានកំណត់នៅក្នុងកថាខ័ណ្ឌ១ ។ -

## មាត្រា៥

រដ្ឋភាគីនិមួយៗត្រូវបង្ក្រាបរាល់បទល្មើសដូចមានចែងក្នុងមាត្រា ៣ ដោយដាក់ទោសសមស្រប ដែលគិតគូរទៅដល់សភាពធ្ងន់ធ្ងរនៃបទល្មើសទាំងនោះ។

## មាត្រា ៦

១- រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការណ៍ចាំបាច់ទាំងឡាយ ដើម្បីបង្កើតនូវយុត្តាធិការរបស់ខ្លួនលើបទល្មើសនានាដូចមានចែងក្នុងមាត្រា៣ នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត:

ក-ប្រឆាំងទៅនឹង ឬ នៅលើនាវាដែលមានដាក់ទង់ជាតិនៃរដ្ឋនោះ នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត ឬ

ខ- នៅក្នុងទឹកដីនៃរដ្ឋនោះ រួមបញ្ចូលទាំងនៅក្នុងសមុទ្រដែនដីនៃរដ្ឋនោះ ឬ

គ- ដោយជនជាតិណាម្នាក់នៃរដ្ឋនោះ

២- រដ្ឋភាគីមួយអាចបង្កើតផងដែរនូវយុត្តាធិការរបស់ខ្លួន លើបទល្មើសបែបណាមួយនោះ នៅពេលដែលៈ

ក- បទល្មើសនោះ ត្រូវបានប្រព្រឹត្តដោយនិរបេតិកជន (ជនដែលគ្មានសញ្ជាតិ) ដែលមានទីលំនៅសេនជ្ជានជា ទំលាប់របស់ខ្លួននៅក្នុងរដ្ឋនោះ ឬ

ខ- ក្នុងកំឡុងពេលនៃការប្រព្រឹត្តបទល្មើសនោះ ជនជាតិណាម្នាក់នៃរដ្ឋនោះត្រូវបានឃាត់ខ្លួន ត្រូវបាន គំរាមកំហែង ត្រូវបានធ្វើអោយរងរបួស ឬ ត្រូវបានសំលាប់ ឬ

គ- បទល្មើសនោះត្រូវបានប្រព្រឹត្តក្នុងបំណងបង្ខិតបង្ខំរដ្ឋនោះអោយធ្វើ ឬ មិនអោយធ្វើនូវអំពើណាមួយ ។

៣- រដ្ឋភាគីនីមួយៗដែលបានបង្កើតយុត្តាធិការលើករណីទាំងឡាយដូចមានចែងនៅក្នុងកថាខ័ណ្ឌ ២ ត្រូវជូនដំណឹង ដល់អគ្គលេខាធិការនៃអង្គការដែនសមុទ្រអន្តរជាតិ (បន្ទាប់ពីនេះហៅថា "អគ្គលេខាធិការ ") ។ បន្ទាប់មក ប្រសិនបើរដ្ឋភាគីនោះលុបចោលនូវយុត្តាធិការនេះ រដ្ឋភាគីនោះត្រូវជូនដំណឹងដល់អគ្គលេខាធិការ ។

៤- រដ្ឋភាគីនិមួយៗត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្កើតនូវយុត្តាធិការរបស់ខ្លួនលើបទល្មើសនានា ដូចមានចែង ក្នុងមាត្រា៣ ក្នុងករណីទាំងឡាយដែលជនល្មើសដោយសន្មតមានវត្តមាននៅក្នុងទឹកដីនៃរដ្ឋនោះ ហើយរដ្ឋនោះមិនធ្វើ បត្យាប័នជនល្មើសនោះទៅអោយរដ្ឋភាគីណាមួយផ្សេងទៀតដែលបានបង្កើតយុត្តាធិការ ដោយអនុលោមតាមកថា ខ័ណ្ឌ១ និង២ នៃមាត្រានេះ ។

៥- អនុសញ្ញានេះ រាប់បញ្ចូលទាំងយុត្តាធិការព្រហ្មទណ្ឌដែលត្រូវបានអនុវត្តស្របទៅតាមច្បាប់ជាតិ ។

## មាត្រា៧

១- ប្រសិនបើស្ថានភាពនានាត្រឹមត្រូវនិងស្របទៅតាមច្បាប់ជាតិរបស់ខ្លួនហើយនោះ រដ្ឋភាគីនីមួយៗដែលជន ល្មើស ឬ ជនល្មើសដោយសន្មតស្ថិតនៅ ត្រូវឃុំខ្លួនជនល្មើសនោះ ឬ ត្រូវចាត់វិធានការចាំបាច់ផ្សេងទៀត ដើម្បីធានា វត្តមានរបស់ជនល្មើសនោះ សំរាប់រយៈពេលមួយចាំបាច់ដើម្បីដំណើរការកាត់ទោស ឬ ដំណើរការនីតិវិធីនៃការ ធ្វើបត្យាប័ន ។

២- រដ្ឋនោះត្រូវធ្វើការស៊ើបអង្កេតបឋមមួយជាបន្ទាន់ ទៅលើហេតុការណ៍ទាំងឡាយ ដោយអនុលោមទៅតាម ច្បាប់ជាតិរបស់ខ្លួន ។

៣- ជនណាម្នាក់ដែលត្រូវបានគេចាត់វិធានការនានា ដូចមានចែងនៅក្នុងកថាខ័ណ្ឌ១ ជននោះត្រូវបានផ្តល់សិទ្ធិដើម្បី ៖

ក- ទាក់ទងជាបន្ទាន់ជាមួយអ្នកតំណាងត្រឹមត្រូវដែលស្ថិតនៅជិតបំផុតនៃរដ្ឋដែលខ្លួនមានសញ្ជាតិ ឬរដ្ឋដែលខ្លួនមានសិទ្ធិបង្កើតទំនាក់ទំនងនោះ ឬប្រសិនបើខ្លួនជានិរបេតិកជន (ជនគ្មានសញ្ជាតិ) ត្រូវទាក់ទងជាមួយរដ្ឋដែលខ្លួនមាននិវេសនដ្ឋានជាទំលាប់នៅក្នុងរដ្ឋនោះ។

ខ- ទទួលបាននូវការសួរសុខទុក្ខដោយអ្នកតំណាងនៃរដ្ឋនោះ។

៤- សិទ្ធិទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ៣ ត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌនៃច្បាប់និងបទបញ្ជាទាំងឡាយ នៃរដ្ឋដែលជនល្មើស ឬ ជនល្មើសដោយសន្មតស្ថិតនៅ ដោយអាស្រ័យលើលក្ខខណ្ឌថាច្បាប់ និង បទបញ្ជាទាំងនោះ ត្រូវធ្វើអោយបានសំរេចពេញលេញនូវគោលបំណង ដែលសិទ្ធិទាំងឡាយត្រូវបានព្រមព្រាងសំរាប់គោលបំណងទាំងនោះ ដូចមានចែងក្នុងកថាខ័ណ្ឌ៣។

៥- នៅពេលណាដែលរដ្ឋភាគីមួយបានឃុំខ្លួនជនណាម្នាក់ ដោយអនុលោមតាមមាត្រានេះ រដ្ឋភាគីនោះត្រូវជូនដំណឹងជាបន្ទាន់ដល់រដ្ឋនានាដែលបានបង្កើតយុត្តាធិការស្របតាមមាត្រា ៦ កថាខ័ណ្ឌ១ និង ប្រសិនបើរដ្ឋភាគីនោះគិតថាគួរធ្វើ ត្រូវជូនដំណឹងដល់រដ្ឋដែលចាប់អារម្មណ៍នានាអំពីហេតុការណ៍ដែលជននោះកំពុងឃុំខ្លួន និង អំពីស្ថានភាពនានាដែលនាំទៅដល់ការចេញដីការឃុំខ្លួននោះ។ រដ្ឋដែលធ្វើការអង្កេតជាបឋម ដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃមាត្រានេះ ត្រូវរាយការណ៍ជាប្រញាប់នូវលទ្ធផលទៅរដ្ឋដែលពោលខាងលើ ហើយត្រូវបញ្ជាក់ថាតើរដ្ឋខ្លួនមានបំណងអនុវត្តយុត្តាធិការ ឬអត់ ។

## មាត្រា៨

១- ប្រធាននាវានៃរដ្ឋភាគី (The flag State រដ្ឋម្ចាស់ទង់ជាតិ) អាចប្រគល់អោយអាជ្ញាធរនៃរដ្ឋភាគីផ្សេងណាមួយទៀត(The receiving State) (រដ្ឋទទួល) នូវជនណាម្នាក់ដែលមានមូលហេតុគ្រប់គ្រាន់ ដែលជឿថាជននោះបានប្រព្រឹត្តបទល្មើសមួយក្នុងចំណោមបទល្មើសទាំងឡាយ ដូចមានចែងក្នុងមាត្រា ៣ ។

២- រដ្ឋម្ចាស់ទង់ជាតិត្រូវធានាថា ប្រធាននាវារបស់ខ្លួនមានកាតព្វកិច្ចជូនដំណឹងទៅអាជ្ញាធរទាំងឡាយនៃរដ្ឋទទួលអំពីបំណងរបស់ខ្លួនដើម្បីប្រគល់ជនណាម្នាក់ និងមូលហេតុផ្សេងៗទៀតដែលបង្ហាញអំពីសេចក្តីសំរេចនេះ នៅពេល

ណាដែលអាចធ្វើទៅបាននិងបើអាច មុនពេលចូលទៅក្នុងសមុទ្រដែនដីនៃរដ្ឋទទួល ដោយមាននាំជននោះដែលប្រធាននាវាមានបំណងយកមកប្រគល់ ដោយអនុលោមតាមកថាខ័ណ្ឌ ១។

៣- រដ្ឋទទួលព្រមទទួលនូវការប្រគល់ខ្លួននោះ លើកលែងតែករណីរដ្ឋនោះមានមូលហេតុដែលអាចចាត់ទុកថា អនុសញ្ញានេះមិនអាចអនុវត្តបានចំពោះអំពើនានាដែលបណ្តាលអោយមានការបញ្ជូនខ្លួន និងត្រូវចាត់និតិវិធី ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៧ ។ រាល់ការបដិសេធទទួលខ្លួនជនណាម្នាក់ត្រូវបង្ហាញពីមូលហេតុនៃការបដិសេធនោះ។

៤- រដ្ឋម្ចាស់ទង់ជាតិត្រូវធានាថាប្រធាននាវារបស់ខ្លួនមានកាតព្វកិច្ចផ្តល់អោយអាជ្ញាធរនានានៃរដ្ឋទទួលនូវ ភស្តុតាងដែលទាក់ទងទៅនឹងបទល្មើសដោយសន្មត។

៥- រដ្ឋទទួលដែលបានទទួលយកការប្រគល់ខ្លួនជនណាម្នាក់ ស្របតាមកថាខ័ណ្ឌ ៣ អាចធ្វើការស្នើសុំរដ្ឋម្ចាស់ទង់ជាតិអោយព្រមទទួលយកជននោះវិញ ។ រដ្ឋម្ចាស់ទង់ជាតិត្រូវពិចារណាសំណើរបែបណាមួយ ហើយប្រសិនបើយល់ព្រមទៅតាមសំណើរនោះ ត្រូវធ្វើតាមនិតិវិធី ស្របតាមមាត្រា ៧ ។ ប្រសិនបើ រដ្ឋម្ចាស់ទង់ជាតិបដិសេធចោលសំណើរមួយ រដ្ឋនោះត្រូវបង្ហាញពីមូលហេតុអំពីសេចក្តីសំរេចនោះដល់រដ្ឋទទួល។

## មាត្រា៩

គ្មានបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះប៉ះពាល់តាមរបៀបណាមួយទៅលើវិធាននៃនិតិអន្តរជាតិ ដែលទាក់ទងទៅនឹងការប្រតិបត្តិសមត្ថកិច្ចនៃរដ្ឋទាំងឡាយក្នុងរឿងស៊ើបអង្កេត ឬការពង្រឹងសមត្ថកិច្ចនៅលើនាវាទាំងឡាយដែលមិនដាក់ទង់ជាតិរបស់ខ្លួន។

## មាត្រា១០

១- ក្នុងករណីដែលមាត្រា៦ត្រូវអនុវត្ត រដ្ឋភាគីដែលជនល្មើស ឬជនល្មើសដោយសន្មតត្រូវបានរកឃើញនៅក្នុងទឹកដីរបស់ខ្លួន ប្រសិនបើរដ្ឋភាគីនោះមិនធ្វើបត្យាប័នជនល្មើសទេ ខ្លួនត្រូវមានកាតព្វកិច្ចដាក់ជូនករណីនេះ ដោយគ្មានការយឺតយ៉ាវនិងគ្មានករណីលើកលែងណាមួយ ទៅអោយអាជ្ញាធរមានសមត្ថកិច្ចទាំងឡាយរបស់ខ្លួនពិនិត្យដើម្បីកាត់

ទោសតាមនិតិវិធី ស្របតាមច្បាប់នៃរដ្ឋនោះ ទោះបីបទល្មើសត្រូវបានឬមិនត្រូវបានប្រព្រឹត្តនៅលើទឹកដីរបស់ខ្លួនក៏ដោយ។ អាជ្ញាធរទាំងនោះត្រូវធ្វើការសំរេចក្នុងលក្ខណៈដូចគ្នា ចំពោះករណីបទល្មើសណាមួយផ្សេងទៀតដែលមានលក្ខណៈធ្ងន់ធ្ងរ ស្របទៅនឹងច្បាប់របស់រដ្ឋនោះ។

២- ជនណាម្នាក់ដែលនិតិវិធីត្រូវអនុវត្តចំពោះខ្លួន ទាក់ទងទៅនឹងបទល្មើសណាមួយក្នុងចំណោមបទល្មើស ទាំងឡាយដូចមានចែងក្នុងមាត្រា៣ ត្រូវបានធានានូវប្រព្រឹត្តកម្មត្រឹមត្រូវ គ្រប់ដំណាក់កាលនៃនិតិវិធី រួមទាំងទទួលបាននូវសិទ្ធិ និង ការធានាទាំងឡាយដូចមានចែងដោយច្បាប់រដ្ឋដែលជននោះស្ថិតនៅ។

## មាត្រា១១

១- បទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា៣ ត្រូវចាត់ទុកដោយរាប់បញ្ចូលជាបទល្មើសដែលធ្វើបត្យាប័នបាននៅក្នុងសន្ធិសញ្ញាបត្យាប័នណាមួយដែលមានរវាងរដ្ឋភាគី។ រដ្ឋភាគីទាំងឡាយត្រូវប្រកាន់យកដោយរាប់បញ្ចូលបទល្មើសទាំងនោះជាបទល្មើសដែលធ្វើបត្យាប័នបាននៅក្នុងរាល់សន្ធិសញ្ញាបត្យាប័នដែលនឹងត្រូវបង្កើតឡើងរវាងរដ្ឋភាគីទាំងនោះ។

២- ប្រសិនបើរដ្ឋភាគីមួយដែលធ្វើបត្យាប័នក្នុងលក្ខខណ្ឌមានសន្ធិសញ្ញា ទទួលសំណើរធ្វើបត្យាប័នពីរដ្ឋភាគីមួយផ្សេងទៀតដែលមិនមានសន្ធិសញ្ញាបត្យាប័ន រដ្ឋភាគីដែលត្រូវបានស្នើសុំ តាមជំរើសរបស់ខ្លួន អាចចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានច្បាប់សំរាប់ការធ្វើបត្យាប័ន ពាក់ព័ន្ធទៅនឹងបទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា៣ ។ ការធ្វើបត្យាប័នត្រូវស្ថិតនៅក្រោមលក្ខខណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់របស់រដ្ឋភាគីដែលត្រូវបានស្នើសុំ។

៣- រដ្ឋភាគីទាំងឡាយដែលមិនដាក់បត្យាប័ននៅក្រោមលក្ខខណ្ឌដែលមានសន្ធិសញ្ញា ត្រូវទទួលស្គាល់បទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា៣ជាបទល្មើសដែលធ្វើបត្យាប័នបានរវាងរដ្ឋទាំងនោះ ក្រោមលក្ខខណ្ឌផ្សេងៗដូចមានចែងក្នុងច្បាប់របស់រដ្ឋភាគីដែលត្រូវបានស្នើសុំ។

៤- ប្រសិនបើចាំបាច់ ក្នុងបំណងធ្វើបត្យាប័នរវាងរដ្ឋភាគី បទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា ៣ ត្រូវបានចាត់ទុកមិនត្រឹមតែជាបទល្មើសដែលបានកើតឡើងនៅទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទេ ថែមទាំងត្រូវបានចាត់ទុកដូចជាបទល្មើសទាំងនោះបានកើតឡើងក្នុងទីកន្លែងដែលឋិតនៅក្រោមសមត្ថកិច្ចនៃរដ្ឋភាគីដែលបានស្នើសុំបត្យាប័នផងដែរ។

៥- រដ្ឋភាគីមួយដែលទទួលសំណើរសំរាប់ធ្វើបត្យាប័នលើសពី ១ ពីបណ្តារដ្ឋដែលបានបង្កើតសមត្ថកិច្ចរបស់ខ្លួន ដោយអនុលោមតាមមាត្រា ៦ និងដែលសំរេចមិនធ្វើការកាត់ទោស កាលបើខ្លួនជ្រើសរើសរដ្ឋដើម្បីធ្វើបត្យាប័នជនល្មើស ឬជនល្មើសដោយសន្មតនោះ ត្រូវគិតគូរទៅដល់ផលប្រយោជន៍ និង ការទទួលខុសត្រូវនៃរដ្ឋភាគីដែលបទល្មើសបានកើតមានឡើងនៅលើនាវាដែលដាក់ទង់ជាតិនៃរដ្ឋភាគីនោះ ។

៦- ដោយអនុលោមតាមអនុសញ្ញានេះ ក្នុងការពិចារណាសំណើរសំរាប់ធ្វើបត្យាប័ននៃជនល្មើសដោយសន្មត រដ្ឋដែលត្រូវបានស្នើសុំត្រូវគិតគូទៅដល់បញ្ហាដែលថាតើសិទ្ធិរបស់ជនល្មើសដោយសន្មតដូចមានចែងក្នុងមាត្រា ៧ កថាខ័ណ្ឌ ៣ អាចអនុវត្តបានដែរឬទេ នៅក្នុងរដ្ឋដែលស្នើសុំ ។

៧- ដោយទាក់ទងទៅនឹងបទល្មើសទាំងឡាយដូចបានកំណត់ច្បាស់នៅក្នុងអនុសញ្ញានេះ បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានិងកិច្ចព្រមព្រាងបត្យាប័នដែលត្រូវបានបង្កើតឡើងរវាងរដ្ឋភាគី ត្រូវកែប្រែរវាងរដ្ឋភាគី ក្នុងលក្ខខណ្ឌដែលបទប្បញ្ញត្តិទាំងនោះវិសមិតជាមួយអនុសញ្ញានេះ ។

**មាត្រា១២**

១- រដ្ឋភាគីទាំងឡាយត្រូវផ្តល់អោយគ្នានូវវិធានការនៃការជួយគ្នាទៅវិញទៅមកផ្នែកយុត្តាធិការ អោយទូលំទូលាយ ក្នុងរាល់នីតិវិធីព្រហ្មទណ្ឌដែលទាក់ទងនឹងបទល្មើសដែលមានចែងក្នុងមាត្រា៣ ដោយរួមមានទាំងការជួយអោយទទួលបាននូវភស្តុតាងចាំបាច់ទាំងឡាយដែលពួកគេអាចប្រើប្រាស់បានសំរាប់និតិវិធី ។

២- រដ្ឋភាគីទាំងឡាយត្រូវអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនទៅតាមកថាខ័ណ្ឌ ១ ស្របជាមួយនឹងសន្ធិសញ្ញាណាមួយស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកយុត្តាធិការដែលអាចមានរវាងគ្នា។ ក្នុងករណីដែលគ្មានសន្ធិសញ្ញាបែបនេះទេ រដ្ឋភាគីត្រូវផ្តល់នូវការជួយគ្នាទៅវិញទៅមកនូវផ្នែកយុត្តាធិការនេះ ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ពួកគេ ។

**មាត្រា១៣**

១- រដ្ឋភាគីត្រូវធ្វើសហប្រតិបត្តិការ ក្នុងការទប់ស្កាត់បទល្មើសដូចមានចែងក្នុងមាត្រា ៣ ជាអាទិ៍ :

ក- ចាត់រាល់វិធានការដែលអាចអនុវត្តបានដើម្បីទប់ស្កាត់រាល់ការរៀបចំនៅក្នុងទឹកដីរៀងៗខ្លួន ក្នុងគោលបំណងប្រព្រឹត្តបទល្មើសទាំងឡាយនៅខាងក្នុង ឬ នៅខាងក្រៅទឹកដីរបស់ខ្លួន ។

ខ- ផ្លាស់ប្តូរពត៌មានដោយអនុលោមតាមច្បាប់ជាតិរបស់ខ្លួន និងសំរបសំរួលវិធានការផ្នែករដ្ឋបាល និង វិធានការផ្សេងៗដែលសមស្រប ដើម្បីទប់ស្កាត់រាល់ការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៣ ។

២- នៅពេលដែលការធ្វើដំណើរឆ្លងកាត់របស់នាវាមួយត្រូវបានពន្យា ឬបង្អាក់ ដោយសារតែការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៣ រដ្ឋភាគីដែលនាវា ឬអ្នកដំណើរ ឬក្រុមនាវិកស្ថិតនៅក្នុងទឹកដីរបស់ខ្លួន ត្រូវប្រឹងប្រែងតាមដែលអាចធ្វើទៅបាន ដើម្បីជៀសវាងនូវការឃាត់ទុក ឬពន្យាដំណើរចំពោះនាវា អ្នកដំណើរ ក្រុមនាវិក ឬទំនិញដោយមិនត្រឹមត្រូវ ។

### មាត្រា១៤

រដ្ឋភាគីណាមួយដែលមានហេតុផលអាចជឿបានថាបទល្មើសមួយដូចមានចែងក្នុងមាត្រា ៣ នឹងត្រូវបានប្រព្រឹត្តឡើង ដោយអនុលោមតាមច្បាប់ជាតិរបស់ខ្លួន ត្រូវផ្តល់ជាបន្ទាន់តាមដែលអាចធ្វើទៅបាននូវពត៌មានពាក់ព័ន្ធដែលខ្លួនមាន ទៅអោយរដ្ឋទាំងឡាយដែលខ្លួនជឿថារដ្ឋទាំងនោះបានបង្កើតសមត្ថកិច្ចរបស់ខ្លួនស្របតាមមាត្រា ៦ ។

### មាត្រា១៥

១- ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន រដ្ឋភាគីនិមួយៗត្រូវផ្តល់ជូនអគ្គលេខាធិការអោយបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននូវពត៌មានដែលពាក់ព័ន្ធណាមួយដែលខ្លួនមាន ទាក់ទងទៅនឹង :

ក- ស្ថានភាពទាំងឡាយនៃបទល្មើស

ខ- វិធានការដែលត្រូវបានចាត់ឡើងដោយអនុលោមតាមមាត្រា១៣ កថាខ័ណ្ឌ២

គ- វិធានការដែលត្រូវបានចាត់ឡើងដែលទាក់ទងទៅនឹងជនល្មើស ឬជនល្មើសដោយសន្មត និង ជាពិសេសរាល់លទ្ធផលនៃនីតិវិធីនៃការធ្វើបត្យាប័នណាមួយ ឬនិតិវិធីផ្នែកយុត្តិធការផ្សេងទៀត ។

២- ដោយអនុលោមតាមច្បាប់ជាតិរបស់ខ្លួន រដ្ឋភាគីដែលបានកាត់ទោសជនល្មើសដោយសន្មត ត្រូវជូនដំណឹងពីលទ្ធផលស្ថាពរនៃនិតិវិធីទាំងនោះទៅអគ្គលេខាធិការ ។

៣- រាល់ព័ត៌មានទាំងឡាយដែលបានទទួលស្របតាមកថាខ័ណ្ឌ១ និង ២ ត្រូវបានផ្សព្វផ្សាយដោយអគ្គលេខាធិការ ទៅគ្រប់រដ្ឋភាគី ទៅសមាជិកទាំងឡាយនៃអង្គការដែនសមុទ្រអន្តរជាតិ (បន្ទាប់ពីនេះហៅថា"អង្គការ" ) ទៅរដ្ឋផ្សេងៗដែលជាប់ពាក់ព័ន្ធ និងទៅអង្គការអន្តររដ្ឋាភិបាលអន្តរជាតិដែលសមស្រប ។

## មាត្រា១៦

១- រាល់ជម្លោះរវាងរដ្ឋភាគី ២ ឬច្រើន ពាក់ព័ន្ធក្នុងការបកស្រាយឬការអនុវត្តន៍នៃអនុសញ្ញានេះ ដែលមិនអាចដោះស្រាយបានតាមរយៈការចរចាក្នុងពេលដ៏សមស្របមួយ ត្រូវដាក់ជូនទៅមជ្ឈត្តវិនិច្ឆ័យទៅតាមសំណើរនៃរដ្ឋភាគីណាមួយ។ ប្រសិនបើក្នុងរយៈពេល ៦ខែ ចាប់ពីថ្ងៃនៃការដាក់សំណើរសំរាប់មជ្ឈត្តវិនិច្ឆ័យ ភាគីទាំងនោះនៅតែមិនអាចឈានទៅដល់ការព្រមព្រៀងលើការរៀបចំមជ្ឈត្តវិនិច្ឆ័យបានទេនោះ ភាគីណាមួយនៃភាគីទាំងនោះអាចដាក់ជំលោះនេះជូនទៅតុលាការយុត្តិធម៌អន្តរជាតិ ដោយដាក់បណ្តឹងអនុលោមទៅតាមលក្ខន្តិកៈ របស់តុលាការ ។

២- នៅពេលចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការព្រមទទួលយក ឬការយល់ព្រមលើអនុសញ្ញានេះ ឬការសុំចូលជាសមាជិក រដ្ឋនិមួយៗអាចប្រកាសថា ខ្លួនមិនចាត់ទុកថាត្រូវបានចងភ្ជាប់ដោយបទប្បញ្ញត្តិណាមួយ ឬដោយរាល់បទប្បញ្ញត្តិនៃកថាខ័ណ្ឌ ១ ទេ។ រដ្ឋភាគីផ្សេងទៀតមិនត្រូវបានចងភ្ជាប់ដោយបទប្បញ្ញត្តិទាំងនោះ ប្រសិនបើមានរដ្ឋភាគីណាមួយ បានដាក់លក្ខខណ្ឌបន្ថែមបែបនេះមួយ។

៣- រដ្ឋណាមួយដែលបានដាក់លក្ខខណ្ឌបន្ថែម អនុលោមតាមកថាខ័ណ្ឌ ២ អាចដកលក្ខខណ្ឌនោះវិញបាន នៅគ្រប់ពេល ដោយជូនដំណឹងទៅអគ្គលេខាធិការ ។

## មាត្រា១៧

១- អនុសញ្ញានេះ ត្រូវបានបើកចំហ នៅទីក្រុងរ៉ូមនាថ្ងៃទី ១០ ខែមិនា ឆ្នាំ ១៩៨៨ សំរាប់ការចុះហត្ថលេខារបស់រដ្ឋទាំងឡាយដែលបានចូលរួមក្នុងសន្និសីទអន្តរជាតិស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ និង ការចុះហត្ថលេខាសំរាប់រដ្ឋទាំងអស់ នៅទីស្នាក់ការនៃអង្គការ ចាប់ពីថ្ងៃទី១៤ ខែ មិនា ឆ្នាំ ១៩៨៨ រហូតដល់ថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ១៩៨៩។ បន្ទាប់មក អនុសញ្ញានេះនៅតែបើកចំហសំរាប់ការចូលជាសមាជិក។

២- រដ្ឋនានាអាចបញ្ជាក់ពីការយល់ព្រមរបស់ខ្លួនក្នុងការគោរពតាមអនុសញ្ញានេះបាន ដោយ :

ក- ការចុះហត្ថលេខាដោយគ្មានលក្ខខណ្ឌផ្តល់សច្ចាប័ន ការព្រមទទួលយក ឬការយល់ព្រម ឬ

ខ- ការចុះហត្ថលេខាដោយឋិតក្រោមលក្ខខណ្ឌសច្ចាប័ន ការព្រមទទួលយក ឬ ការយល់ព្រមដែលតំរូវផ្តល់សច្ចាប័ន ការព្រមទទួលយក ឬ ការយល់ព្រម ឬ

គ- ការចូលជាសមាជិក ។

៣- ការផ្តល់សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិក មានប្រសិទ្ធិភាព ដោយការដាក់ជូននូវលិខិតុបករណ៍មួយទៅអគ្គលេខាធិការ ។

### មាត្រា១៨

១- អនុសញ្ញានេះចូលជាធរមាននៅ ៩០ ថ្ងៃ បន្ទាប់ពីរដ្ឋចំនួន ១៥ បានចុះហត្ថលេខាលើអនុសញ្ញានេះ ដោយគ្មានលក្ខខណ្ឌផ្តល់សច្ចាប័ន ការព្រមទទួលយក ឬ ការយល់ព្រម ឬបានដាក់លិខិតុបករណ៍សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិក ។

២- ចំពោះរដ្ឋមួយដែលដាក់លិខិតុបករណ៍សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិក នៃអនុសញ្ញានេះ បន្ទាប់ពីលក្ខខណ្ឌនានាសំរាប់ចូលជាធរមានត្រូវបានបំពេញរួចហើយនោះ សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិក ចាប់មានសុពលភាព ៩០ ថ្ងៃ បន្ទាប់ពីថ្ងៃនៃការដាក់លិខិតុបករណ៍ ។

### មាត្រា១៩

១- អនុសញ្ញានេះ អាចត្រូវបានប្រកាសមិនយល់ព្រមដោយរដ្ឋភាគីណាមួយ នៅពេលណាក៏បាន បន្ទាប់ពីផុតកំណត់រយៈពេល១ឆ្នាំ ចាប់ពីថ្ងៃដែលអនុសញ្ញានេះចូលជាធរមានសំរាប់រដ្ឋនោះ ។

២- ការប្រកាសមិនយល់ព្រម អាចមានសុពលភាពបាន ដោយការដាក់លិខិតុបករណ៍នៃការប្រកាសមិនយល់ព្រមនោះ ជូនទៅអគ្គលេខាធិការ ។

៣- សេចក្ដីប្រកាសមិនយល់ព្រម ចាប់មានសុពលភាពរយៈពេល ១ឆ្នាំ ឬក៏រយៈពេលយូរជាងនេះដូចដែលបានបញ្ជាក់នៅក្នុងលិខិតុបករណ៍នៃសេចក្ដីប្រកាសមិនយល់ព្រម បន្ទាប់ពីការទទួលលិខិតុបករណ៍នៃសេចក្ដីប្រកាសមិនយល់ព្រមនេះ ដោយអគ្គលេខាធិការ ។

## មាត្រា២០

១- សន្និសីទមួយអាចត្រូវបានកោះប្រជុំ ដោយ"អង្គការ" សំរាប់គោលបំណងពិនិត្យឡើងវិញ ឬ វិសោធនកម្មលើអនុសញ្ញានេះ ។

២- អគ្គលេខាធិការ អាចកោះប្រជុំរដ្ឋភាគីទាំងឡាយនៃអនុសញ្ញានេះ ដើម្បីធ្វើសន្និសីទពិនិត្យឡើងវិញ ឬ វិសោធនកម្មអនុសញ្ញានេះ ទៅតាមសំណើរចំនួន ១ភាគ៣នៃរដ្ឋភាគី ឬ រដ្ឋភាគីចំនួន ១០ ប្រសិនបើតួលេខខាងក្រោយនេះខ្ពស់ជាង ។

៣- លិខិតុបករណ៍ណាមួយនៃការផ្ដល់សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬការចូលជាសមាជិក ដែលត្រូវបានដាក់ជូន បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃវិសោធនកម្មលើអនុសញ្ញានេះ ត្រូវបានចាត់ទុកថាអនុវត្តតាមអនុសញ្ញាដែលបានធ្វើវិសោធនកម្មរួច ។

## មាត្រា២១

១- អនុសញ្ញានេះត្រូវបានតំកល់ទុកនៅអគ្គលេខាធិការ ។

២- អគ្គលេខាធិការត្រូវ :

ក- ផ្ដល់ពត៌មានដល់រដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញានេះ ឬ បានចូលជាសមាជិកនៃអនុសញ្ញានេះ ព្រមទាំងសមាជិកទាំងអស់នៃអង្គការនេះអោយបានដឹងអំពី :

(១)- ហត្ថលេខាថ្មីនិមួយៗ ឬការដាក់លិខិតុបករណ៍ថ្មីនៃសច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬការចូលជាសមាជិក ព្រមទាំងកាលបរិច្ឆេទ

(២)- កាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ

(៣)- ការដាក់ដឹកល់លិខិតុបករណ៍ណាមួយនៃសេចក្តីប្រកាសមិនយល់ព្រមលើអនុសញ្ញានេះ រួមទាំងកាលបរិច្ឆេទដែលបានទទួល និង កាលបរិច្ឆេទដែលសេចក្តីប្រកាសមិនយល់ព្រមចាប់មានសុពលភាព ។

(៤)- ការទទួលនៃសេចក្តីប្រកាស ឬសេចក្តីជូនដំណឹងណាមួយដែលបានធ្វើឡើងស្របតាមអនុសញ្ញានេះ ។

ខ- បញ្ជូនឯកសារចំលងពិតដែលបានបញ្ជាក់ជាផ្លូវការនៃអនុសញ្ញានេះ ទៅអោយរដ្ឋទាំងអស់ដែលបានចុះហត្ថលេខា ឬ បានចូលជាសមាជិកនៃអនុសញ្ញានេះ ។

៣- នៅពេលដែលអនុសញ្ញានេះចូលជាធរមាន ឯកសារចំលងពិតដែលបានបញ្ជាក់ជាផ្លូវការនោះ ត្រូវបានបញ្ជូនដោយអ្នកថែរក្សាឯកសារទៅជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ សំរាប់ការចុះបញ្ជីនិងផ្សព្វផ្សាយ ដោយអនុលោម ទៅតាមមាត្រា១០២ នៃធម្មនុញ្ញសហប្រជាជាតិ ។

## មាត្រា ២២

អនុសញ្ញានេះ ត្រូវបានរៀបរៀងឡើងជាច្បាប់ដើមតែមួយ ជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្បាញ ដែលអត្ថបទនីមួយៗមានតំលៃស្មើគ្នា ។

**ដើម្បីជាសាក្សីនារា** អ្នកដែលចុះហត្ថលេខាខាងក្រោម ត្រូវបានផ្តល់សិទ្ធិអោយដ៏ត្រឹមត្រូវ ដោយរដ្ឋាភិបាលរបស់ខ្លួនរៀងៗខ្លួនសំរាប់វត្ថុបំណងនោះ បានចុះហត្ថលេខាលើអនុសញ្ញានេះ ។

ធ្វើនៅទីក្រុងរ៉ូម ថ្ងៃទី ១០ ខែ មិនា ឆ្នាំ១៩៨៨ ។

# Convention for the Supression of Unlawful Acts Against the Safety of Maritime Navigation

Signed at Rome, 10 March 1988

THE STATES PARTIES to this Convention,

HAVING IN MIND the purposes and principles of the Charter of the United Nations concerning the maintenance of international peace and security and the promotion of friendly relations and co-operation among States,

RECOGNIZING in particular that everyone has the right to life, liberty and security of person, as set out in the Universal Declaration of Human Rights and the International Covenant on Civil and Political Rights,

DEEPLY CONCERNED about the world-wide escalation of acts of terrorism in all its forms, which endanger or take innocent human lives, jeopardize fundamental freedoms and seriously impair the dignity of human beings,

CONSIDERING that unlawful acts against the safety of maritime navigation jeopardize the safety of persons and property, seriously affect the operation of maritime services, and undermine the confidence of the peoples of the world in the safety of maritime navigation,

CONSIDERING that the occurrence of such acts is a matter of grave concern to the international community as a whole,

BEING CONVINCED of the urgent need to develop international co-operation between States in devising and adopting effective and practical measures for the prevention of all unlawful acts against the safety of maritime navigation, and the prosecution and punishment of their perpetrators,

RECALLING resolution 40/61 of the General Assembly of the United Nations of 9 December 1985 which, inter alia, "urges all States unilaterally and in co-operation with other States, as well as relevant United Nations organs, to contribute to the progressive elimination of causes underlying international terrorism and to pay special attention to all situations, including colonialism, racism and situations involving mass and flagrant violations of human rights and fundamental freedoms and those involving alien occupation, that may give rise to international terrorism and may endanger international peace and security",

RECALLING FURTHER that resolution 40/61 "unequivocally condemns, as criminal) all acts, methods and practices of terrorism wherever and by whomever committed, including those which jeopardize friendly relations among States and their security",

RECALLING ALSO that by resolution 40/61, the International Maritime Organization was invited to "study the problem of terrorism aboard or against ships with a view to making recommendations on appropriate measures",

HAVING IN MIND resolution A.584(14) of 20 November 1985, of the Assembly of the International Maritime Organization, which called for development of measures to prevent

unlawful acts which threaten the safety of ships and the security of their passengers and crews,

NOTING that acts of the crew which are subject to normal shipboard discipline are outside the purview of this Convention,

AFFIRMING the desirability of monitoring rules and standards relating to the prevention and control of unlawful acts against ships and persons on board ships, with a view to updating them as necessary, and, to this effect, taking note with satisfaction of the Measures to Prevent Unlawful Acts against Passengers and Crews on Board Ships, recommended by the Maritime Safety Committee of the International Maritime Organization,

AFFIRMING FURTHER that matters not regulated by this Convention continue to be governed by the rules and principles of general international law,

RECOGNIZING the need for all States, in combating unlawful acts against the safety of maritime navigation, strictly to comply with rules and principles of general international law,

HAVE AGREED as follows:

**ARTICLE 1**

For the purposes of this Convention, "ship" means a vessel of any type whatsoever not permanently attached to the sea-bed, including dynamically supported craft, submersibles, or any other floating craft.

**ARTICLE 2**

1. This Convention does not apply to:
   a. a warship; or
   b. a ship owned or operated by a State when being used as a naval auxiliary or for customs or police purposes; or
   c. a ship which has been withdrawn from navigation or laid up.
2. Nothing in this Convention affects the immunities of warships and other government ships operated for non-commercial purposes.

**ARTICLE 3**

1. Any person commits an offence if that person unlawfully and intentionally:
   a. seizes or exercises control over a ship by force or threat thereof or any other form of intimidation; or
   b. performs an act of violence against a person on board a ship if that act is likely to endanger the safe navigation of that ship; or
   c. destroys a ship or causes damage to a ship or to its cargo which is likely to endanger the safe navigation of that ship; or
   d. places or causes to be placed on a ship, by any means whatsoever, a device or substance which is likely to destroy that ship, or cause damage to that ship or its cargo which endangers or is likely to endanger the safe navigation of that ship; or
   e. destroys or seriously damages maritime navigational facilities or seriously interferes with their operation, if any such act is likely to endanger the safe navigation of a ship; or
   f. communicates information which he knows to be false, thereby endangering the safe navigation of a ship; or

g. injures or kills any person, in connection with the commission or the attempted commission of any of the offences set forth in subparagraphs (a) to (f).

2. Any person also commits an offence if that person:
   a. attempts to commit any of the offences set forth in paragraph 1; or
   b. abets the commission of any of the offences set forth in paragraph 1 perpetrated by any person or is otherwise an accomplice of a person who commits such an offence; or
   c. threatens, with or without a condition, as is provided for under national law, aimed at compelling a physical or juridical person to do or refrain from doing any act, to commit any of the of fences set forth in paragraph 1, subparagraphs (b), (c) and (e), if that threat is likely to endanger the safe navigation of the ship in question.

**ARTICLE 4**

1. This Convention applies if the ship is navigating of is scheduled to navigate into, through or from waters beyond the outer limit of the territorial sea of a single State, or the lateral limits of its territorial sea with adjacent States.
2. In cases where the Convention does not apply pursuant to paragraph 1, it nevertheless applies when the offender or the alleged offender is found in the territory of a State Party other than the State referred to in paragraph 1.

**ARTICLE 5**

Each State Party shall make the offences set forth in article 3 punishable by appropriate penalties which take into account the grave nature of those offences.

**ARTICLE 6**

1. Each State Party shall take such measures as may be necessary to establish its jurisdiction over the offences set forth in article 3 when the offence is committed:
   a. against or on board a ship flying the flag of the State at the time the offence is committed; or
   b. in the territory of that State, including its territorial sea; or
   c. by a national of that State.
2. A State Party may also establish its jurisdiction over any such offence when:
   a. it is committed by a stateless person whose habitual residence is in that State; or
   b. during its commission a national of that State is seized, threatened, injured or killed; or
   c. it is committed in an attempt to compel that State to do or abstain from doing any act.
3. Any State Party which has established jurisdiction mentioned in paragraph 2 shall notify the Secretary-General of the International Maritime Organization (hereinafter referred to as "the Secretary-General"). If such State Party subsequently rescinds that jurisdiction, it shall notify the Secretary-General.
4. Each State Party shall take such measures as may be necessary to establish its jurisdiction over the offences set forth in article 3 in cases where the alleged offender is present in its territory and it does not extradite him to any of the States Parties which have established their jurisdiction in accordance with paragraphs 1 and 2 of this article.
5. This Convention does not exclude any criminal jurisdiction exercised in accordance with national law.

**ARTICLE 7**

1. Upon being satisfied that the circumstances so warrant, any State Party in the territory of which the offender or the alleged offender is present shall, in accordance with its law, take him into custody or take other measures to ensure his presence for such time as is necessary to enable any criminal or extradition proceedings to be instituted.
2. Such State shall immediately make a preliminary inquiry into the facts, in accordance with its own legislation.
3. Any person regarding whom the measures referred to in paragraph 1 are being taken shall be entitled to:
    a. communicate without delay with the nearest appropriate representative of the State of which he is a national or which is otherwise entitled to establish such communication or, if he is a stateless person, the State in the territory of which he has his habitual residence;
    b. be visited by a representative of that State.
4. The rights referred to in paragraph 3 shall be exercised in conformity with the laws and regulations of the State in the territory of which the offender or the alleged offender is present, subject to the proviso that the said laws and regulations must enable full effect to be given to the purposes for which the rights accorded under paragraph 3 are intended.
5. When a State Party, pursuant to this article, has taken a person into custody, it shall immediately notify the States which have established jurisdiction in accordance with article 6, paragraph 1 and, if it considers it advisable, any other interested States, of the fact that such person is in custody and of the circumstances which warrant his detention. The State which makes the preliminary inquiry contemplated in paragraph 2 of this article shall promptly report its findings to the said States and shall indicate whether it intends to exercise jurisdiction.

## ARTICLE 8

1. The master of a ship of a State Party (the "flag State") may deliver to the authorities of any other State Party (the "receiving State") any person who he has reasonable grounds to believe has committed one of the offences set forth in article 3.
2. The flag State shall ensure that the master of its ship is obliged, whenever practicable, and if possible before entering the territorial sea of the receiving State carrying on board any person whom the master intends to deliver in accordance with paragraph 1, to give notification to the authorities of the receiving State of his intention to deliver such person and the reasons therefor.
3. The receiving State shall accept the delivery, except where it has grounds to consider that the Convention is not applicable to the acts giving rise to the delivery, and shall proceed in accordance with the provisions of article 1. Any refusal to accept a delivery shall be accompanied by a statement of the reasons for refusal.
4. The flag State shall ensure that the master of its ship is obliged to furnish the authorities of the receiving State with the evidence in the master's possession which pertains to the alleged offence.
5. A receiving State which has accepted the delivery of a person in accordance with paragraph 3 may, in turn, request the flag State to accept delivery of that person. The flag State shall consider any such request, and if it accedes to the request it shall proceed in accordance with article 7. If the flag State declines a request, it shall furnish the receiving State with a statement of the reasons therefor.

## ARTICLE 9

Nothing in this Convention shall affect in any way the rules of international law pertaining to the competence of States to exercise investigative or enforcement jurisdiction on board ships not flying their flag.

## ARTICLE 10

1. The State Party in the territory of which the offender or the alleged offender is found shall, in cases to which article 6 applies, if it does not extradite him, be obliged, without exception whatsoever and whether or not the offence was committed in its territory, to submit the case without delay to its competent authorities for the purpose of prosecution, through proceedings in accordance with the laws of that State. Those authorities shall take their decision in the same manner as in the case of any other offence of a grave nature under the law of that State.
2. Any person regarding whom proceedings are being carried out in connection with any of the offences set forth in article 3 shall be guaranteed fair treatment at all stages of the proceedings, including enjoyment of all the rights and guarantees provided for such proceedings by the law of the State in the territory of which he is present.

ARTICLE 11

1. The offences set forth in article 3 shall be deemed to be included as extraditable offences in any extradition treaty existing between any of the States Parties. States Parties undertake to include such offences as extraditable offences in every extradition treaty to be concluded between them.
2. If a State Party which makes extradition conditional on the existence of a treaty receives a request for extradition from another State Party with which it has no extradition treaty, the requested State Party may, at its option, consider this Convention as a legal basis for extradition in respect of the offences set forth in article 3. Extradition shall be subject to the other conditions provided by the law of the requested State Party.
3. States Parties which do not make extradition conditional on the existence of a treaty shall recognize the offences set forth in article 3 as extraditable offences between themselves, subject to the conditions provided by the law of the requested State.
4. If necessary, the offences set forth in article 3 shall be treated, for the purposes of extradition between States Parties, as if they had been committed not only in the place in which they occurred but also in a place within the jurisdiction of the State Party requesting extradition.
5. A State Party which receives more than one request for extradition from States which have established jurisdiction in accordance with article 7 and which decides not to prosecute shall, in selecting the State to which the offender or alleged offender is to be extradited, pay due regard to the interests and responsibilities of the State Party whose flag the ship was flying at the time of the commission of the offence.
6. In considering a request for the extradition of an alleged offender pursuant to this Convention, the requested State shall pay due regard to whether his rights as set forth in article 7, paragraph 3, can be effected in the requesting State.
7. With respect to the offences as defined in this Convention, the provisions of all extradition treaties and arrangements applicable between States Parties are modified as between States Parties to the extent that they are incompatible with this Convention.

ARTICLE 12

1. State Parties shall afford one another the greatest measure of assistance in connection with criminal proceedings brought in respect of the offences set forth in article 3, including assistance in obtaining evidence at their disposal necessary for the proceedings.
2. States Parties shall carry out their obligations under paragraph 1 in conformity with any treaties on mutual assistance that may exist between them. In the absence of such treaties, States Parties shall afford each other assistance in accordance with their national law.

ARTICLE 13

1. States Parties shall co-operate in the prevention of the offences set forth in article 3, particularly by:
   a. taking all practicable measures to prevent preparations in their respective territories for the commission of those offences within or outside their territories;
   b. exchanging information in accordance with their national law, and co-ordinating administrative and other measures taken as appropriate to prevent the commission of offences set forth in article 3.
2. When, due to the commission of an offence set forth in article 3, the passage of a ship has been delayed or interrupted, any State Party in whose territory the ship or passengers or crew are present shall be bound to exercise all possible efforts to avoid a ship, its passengers, crew or cargo being unduly detained or delayed.

**ARTICLE 14**

Any State Party having reason to believe that an offence set forth in article 3 will be committed shall, in accordance with its national law, furnish as promptly as possible any relevant information in its possession to those States which it believes would be the States having established jurisdiction in accordance with article 6.

**ARTICLE 15**

1. Each State Party shall, in accordance with its national law) provide to the Secretary-General, as promptly as possible, any relevant information in its possession concerning:
   a. the circumstances of the offence;
   b. the action taken pursuant to article 13, paragraph 2;
   c. the measures taken in relation to the offender or the alleged offender and, in particular, the results of any extradition proceedings or other legal proceedings.
2. The State Party where the alleged offender is prosecuted shall, in accordance with its national law, communicate the final outcome of the proceedings to the Secretary-General.
3. The information transmitted in accordance with paragraphs 1 and 2 shall be communicated by the Secretary-General to all States Parties, to Members of the International Maritime Organization (hereinafter referred to as "the Organization"), to the other States concerned, and to the appropriate international intergovernmental organizations.

**ARTICLE 16**

1. Any dispute between two or more States Parties concerning the interpretation or application of this Convention which cannot be settled through negotiation within a reasonable time shall, at the request of one of them, be submitted to arbitration. If, within six months from the date of the request for arbitration, the parties are unable to agree on the organization of the arbitration any one of those parties may refer the dispute to the International Court of Justice by request in conformity with the Statute of the Court.
2. Each State may at the time of signature or ratification, acceptance or approval of this Convention or accession thereto, declare that it does not consider itself bound by any or all of the provisions of paragraph 1. The other States Parties shall not be bound by those provisions with respect to any State Party which has made such a reservation.
3. Any State which has made a reservation in accordance with paragraph 2 may, at any time, withdraw that reservation by notification to the Secretary-General.

**ARTICLE 17**

1. This Convention shall be open for signature at Rome on 10 March 1988 by States participating in the International Conference on the Suppression of Unlawful Acts against the Safety of Maritime Navigation and at the Headquarters of the Organization by all States from 14 March 1988 to 9 March 1989. It shall thereafter remain open for accession.
2. States may express their consent to be bound by this Convention by:
   a. signature without reservation as to ratification, acceptance or approval; or
   b. signature subject to ratification, acceptance or approval, followed by ratification, acceptance or approval; or
   c. accession.
3. Ratification, acceptance, approval or accession shall be effected by the deposit of an instrument to that effect with the Secretary-General.

**ARTICLE 18**

1. This Convention shall enter into force ninety days following the date on which fifteen States have either signed it without reservation as to ratification, acceptance or approval, or have deposited an instrument of ratification, acceptance, approval or accession in respect thereof.
2. For a State which deposits an instrument of ratification, acceptance, approval or accession in respect of this Convention after the conditions for entry into force thereof have been met, the ratification, acceptance, approval or accession shall take effect ninety days after the date of such deposit.

**ARTICLE 19**

1. This Convention may be denounced by any State Party at any time after the expiry of one year from the date on which this Convention enters into force for that State.
2. Denunciation shall be effected by the deposit of an instrument of denunciation with the Secretary-General.
3. A denunciation shall take effect one year, or such longer period as may be specified in the instrument of denunciation, after the receipt of the instrument of denunciation by the Secretary-General.

**ARTICLE 20**

1. A conference for the purpose of revising or amending this Convention may be convened by the Organization.
2. The Secretary-General shall convene a conference of the States Parties to this Convention for revising or amending the Convention, at the request of one third of the States Parties, or ten States Parties, whichever is the higher figure.
3. Any instrument of ratification, acceptance, approval or accession deposited after the date of entry into force of an amendment to this Convention shall be deemed to apply to the Convention as amended.

**ARTICLE 21.**

1. This Convention shall be deposited with the Secretary-General.
2. The Secretary-General shall:
   a. inform all States which have signed this Convention or acceded thereto, and all Members of the Organization, of:
      i. each new signature or deposit of an instrument of ratification, acceptance, approval or accession together with the date thereof;
      ii. the date of the entry into force of this Convention;
      iii. the deposit of any instrument of denunciation of this Convention together with the date on which it is received and the date on which the denunciation takes effect;